ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*ថ្ងៃ ចន្ទ ៥ កើត ខែ អស្សុជ ឆ្នាំ រោង ឆស័ក ព.ស. ២៥៦៨*
*រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ តុលា គ.ស. ២០២៤*

# សេចក្ដីប្រកាសព័ត៌មាន
# ស្ដីពីជំនួបសម្ដែងការគួរសមរវាង
# ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
# ជាមួយលោក Robert Kaproth ឧបការីរងទទួលបន្ទុកតំបន់អាស៊ីនៃ
# ក្រសួងរតនាគារសហរដ្ឋអាមេរិក

នារសៀលថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០២៤, នៅទីស្ដីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបពិភាក្សាការងារជាមួយលោក Robert Kaproth ឧបការីរងទទួលបន្ទុកតំបន់អាស៊ី នៃក្រសួងរតនាគារសហរដ្ឋអាម៉េរិក (US Depertment of the Treasury) ។

ជាមួយនឹងកិច្ចស្វាគមន៍យ៉ាងកក់ក្ដៅ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដំណើរទស្សនកិច្ចស្វែងយល់អំពីវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា ក៏ដូចជាដើម្បីពង្រឹងបន្ថែមទៀតកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា- អាមេរិករបស់លោក Robert Kaproth នៅកម្ពុជា, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានជម្រាបជូនជារួមអំពីការការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការដាក់ចេញនូវគោលនយោបាយ យុទ្ធសាស្ត្រ និងវិធានការនានា ដើម្បីកំណើនសង្គម-សេដ្ឋកិច្ចនៅកម្ពុជា ។ ជាមួយគ្នានេះ, ទោះបីជាមានភាពមិនប្រាកដប្រជាខ្ពស់នៃកត្តាខាងក្រៅ, កម្ពុជា បានប្រកាន់យកគោលដៅក្នុងការសម្រេចកំណើនសេដ្ឋកិច្ចឱ្យបាន ៦,០% ក្នុងឆ្នាំ ២០២៤ និង ៦,៣%ឆ្នាំ ២០២៥ ។ ជាក់ស្ដែង, រាជរដ្ឋាភិបាល បាននិងកំពុងរៀបចំគោលនយោបាយ និងយន្តការនានាក្នុងការបង្កើនប្រសិទ្ធភាពចំណូល-ចំណាយ, ការគ្រប់គ្រងសេដ្ឋកិច្ច, ហិរញ្ញវត្ថុសាធារណៈ ដែលរួមចំណែកដល់ការរក្សាភាពធន់សេដ្ឋកិច្ច រួមមាន "**យុទ្ធសាស្ត្រប្រមូលចំណូល២០២៤-២០២៨**" និង "**កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និង ពង្រឹង**

**ភាពធន់ ដើម្បីកំណើនសេដ្ឋកិច្ច នៅក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់ឆ្នាំ ២០២៤-២០២៨**" ជាដើម ។ ជារួម, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងបន្តសហការរីករាយជាមួយ ភាគីអាម៉េរិកក្នុងការសម្របសម្រួល ជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគីជាពិសេសការពង្រីក ពាណិជ្ជកម្ម និងការវិនិយោគរវាងប្រទេសទាំងពីរ ដែលនឹងផ្តល់ប្រយោជន៍ទៅវិញទៅមក ។

លោក Robert Kaproth បានបង្ហាញសុទិដ្ឋិនិយមខ្ពស់នូវកិច្ចខិតខំរបស់កម្ពុជាក្នុងការ គ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និងលទ្ធផលល្អនានាដែលកម្ពុជាទទួលបាននាពេល កន្លងមក ក៏ដូចជាគោលដៅរយៈពេលវែងខាងមុខ ដែលរាជរដ្ឋាភិបាល បាននិងកំពុងខិតខំ បង្កើតឡើងក្នុងការជំរុញកំណើន និងការអភិវឌ្ឍសេដ្ឋកិច្ច ។ ជាមួយគ្នានេះ, លោក Robert Kaproth បានធ្វើការកោតសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជាការខិតខំ បន្តដោះស្រាយបញ្ហា ប្រឈមនានារបស់ខ្លួន និងស្វែងរកដំណោះស្រាយទាំងក្នុងកម្រិតគោលនយោបាយ និងបច្ចេកទេស ។

ភាគីទាំងពីរ ក៏បានបញ្ជាក់អំពីគោលដៅរួមគ្នា ក្នុងការខិតខំជំរុញកិច្ចសហប្រតិបត្តិការ ទ្វេភាគី រវាងប្រទេសទាំងពីរកម្ពុជា-អាមេរិកាំង លើគ្រប់វិស័យ ឲ្យកាន់តែរឹងមាំនិងស៊ីជម្រៅថែម ទៀត ។

ជាទីបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាថ្មីម្តង ទៀត ចំពោះលោក Robert Kaproth ក្នុងការខិតខំស្វែងយល់អំពីស្ថានភាពរបស់កម្ពុជា និងសង្ឃឹម ខ្ពស់ ដល់ភាគីអាម៉េរិកក្នុងការរក្សាជំនួយបច្ចេកទេសផ្សេងៗនៅក្នុងវិស័យអាទិភាពកម្ពុជានិងជូន ពរលោក Robert Kaproth និងក្រុមការងារទទួលបានជោគជ័យជាផ្លែផ្កាក្នុងទស្សនកិច្ចនៅកម្ពុជា ។